01202792

F2/10/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Feb-2016, 14:27
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៦
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

---

# សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំការពិចារណាឡើងវិញនូវសេចក្តីសម្រេច កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ស្តីពីសំណើសុំដាក់ភស្តុតាងបន្ថែម

---

**សហព្រះរាជអាជ្ញា** | **សហមេធាវីជនជាប់ចោទ នួន ជា**

ជា លាង

Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

សុន អរុណ

Victor KOPPE

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**" នីមួយៗ),

**បានទទួល**"សំណើរបស់ នួន ជា សុំធ្វើការពិចារណាឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេច មិនកោះហៅ ហេង សំរិន និង Robert LEMKIN និង[មិន]ទទួលយកភស្តុតាងលើបណ្តឹងសាទុក្ខដែលបានផលិតដោយ Robert LEMKIN" ដែលត្រូវបានដាក់នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("សំណើសុំ")[1],

**កត់សម្គាល់ឃើញ**ថា នួន ជា បានអះអាងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលកាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ លើសំណើរបស់គាត់សុំដាក់ភស្តុតាងបន្ថែមនៅចំពោះមុខ("សេចក្តីសម្រេចលើភស្តុតាងបន្ថែម")[2] មានកំហុសទាំងស្រុង ដោយសារតែ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធសំណើសុំរបស់គាត់មួយភាគធំ ដែលបើតាមយោបល់របស់គាត់ ភស្តុតាងទាំងនេះ មានសារៈសំខាន់បំផុត មានលក្ខណៈពិសេស និងជាស្នូលសំខាន់ចំពោះរឿងក្តីរបស់ភាគីការពារក្តី រួមទាំងការតវ៉ាទៅលើលក្ខខណ្ឌតម្រូវស្តីពីភាពអាចទទួលយកបានដែលពាក់ព័ន្ធផងដែរ[3],

**កត់សម្គាល់ឃើញ**ថា នួន ជា លើកឡើងថា សិទ្ធិអំណាចរបស់អង្គជំនុំជម្រះក្នុងការពិចារណាឡើងវិញ អាចអនុវត្តបានមិនត្រឹមតែក្នុងករណីដែលមាន"កាលៈទេសៈប្រែប្រួល"ប៉ុណ្ណោះទេ ថែមទាំងក្នុងករណីដែលសេចក្តីសម្រេចពីមុន"មានកំហុស ឬ [...] បណ្តាលឱ្យមានភាពអយុត្តិធម៌"[4] និងថា សិទ្ធិដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ក្នុងការទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ ត្រូវអនុវត្តចំពោះការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល[5] និងដោយផ្អែកលើមូលដ្ឋាននេះ នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណាការសម្រេចរបស់ខ្លួនឡើងវិញលើភស្តុតាងបន្ថែម ដែលបានបដិសេធសំណើរបស់គាត់សុំកោះហៅ ហេង សំរិន និង Robert LEMKIN និងសុំឱ្យទទួលយកធ្វើជាភស្តុតាងនូវឯកសារដែល

---

[1] ឯកសារលេខ F2/10។

[2] សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែមនៅចំពោះមុខលើបណ្តឹងសាទុក្ខ និងបញ្ហាពាក់ព័ន្ធផ្សេងៗ–ផ្នែកសម្រេចសេចក្តី ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F2/9។

[3] សំណើសុំ កថាខណ្ឌ ៤ ដល់ ៦, ១៧, ៣២ ដល់ ៣៣, ៤៥ និង ៥៦។

[4] សំណើសុំ កថាខណ្ឌ ២៩ ដល់ ៣០។

[5] សំណើសុំ កថាខណ្ឌ ៣១។

បានផលិតដោយ Robert LEMKIN ឬជាជម្រើស ផ្តល់សំអាងហេតុពេញលេញសម្រាប់សេចក្តីសម្រេចរបស់ខ្លួនលើភស្តុតាងបន្ថែមមុនពេលបន្តសវនាការលើបណ្តឹងសាទុក្ខ[6],

**កត់សម្គាល់ឃើញ**ថា សហព្រះរាជអាជ្ញា មួយផ្នែកបានជំទាស់ទៅនឹងសំណើរបស់ នួន ជា សុំការពិចារណាឡើងវិញ និងបានសង្កេតឃើញថា សំណើនេះ ជា“ការលើកឡើងច្រំដែល និងពុំមានការជាប់ពាក់ព័ន្ធ” និងពុំមានការលើកភស្តុតាងគាំទ្រអង្គហេតុថ្មី ឬការប្រែប្រួលនៃកាលៈទេសៈណាមួយឡើយ[7] ហើយមួយផ្នែកទៀត ពុំបានជំទាស់ទៅនឹងសំណើរបស់ នួន ជា ដែលសុំជាជម្រើសឱ្យអង្គជំនុំជម្រះតុលាការកំពូលផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួនលើភស្តុតាងបន្ថែម ប៉ុន្តែទោះជាយ៉ាងណាក្តី បានចង្អុលបង្ហាញថា សំណើសុំដែលជាម្រើសនេះ មានលក្ខណៈយឺតពេល[8],

**រំលឹក**ថា ដើម្បីឱ្យស្របជាមួយនឹងការអនុវត្តតាមលក្ខណៈអន្តរជាតិ[9] អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចទៅលើសំណើសុំការពិចារណាឡើងវិញ ក្នុងករណីដែលមាន“មូលហេតុដែលគួរឱ្យជឿបាន រួមទាំងការប្រែប្រួលនៃកាលៈទេសៈណាមួយ” ដែលតម្រូវឱ្យមានការពិចារណាឡើងវិញនូវសេចក្តីសម្រេចពី

---

[6] សំណើសុំ កថាខណ្ឌ ៥៧ ដល់ ៥៨។

[7] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំការពិចារណារឡើងវិញនូវសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចមិនកោះហៅ ហេង សំរិន និង Robert LEMKIN និងមិនទទួលយកភស្តុតាង ដែលបានផលិតដោយ Robert LEMKIN លើបណ្តឹងសាទុក្ខ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារលេខ F2/10/2 (“សារណាតប”) កថាខណ្ឌ ២ ដល់ ៥ និង ៧។

[8] សារណាតប កថាខណ្ឌ ៦។

[9] *សូមមើលឧ. រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Ruto និង Sang* សំណុំរឿងលេខ ICC-01/09-01/11 “សេចក្តីសម្រេចលើសំណើរបស់ភាគីការពារក្តីសុំការពិចារណាឡើងវិញអំពីការកំណត់ទំព័រ និងពេលវេលា” អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ កថាខណ្ឌ ១៩។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Galić* សំណុំរឿងលេខ IT-98-29-T “សេចក្តីសម្រេចលើសំណើរបស់ភាគីការពារក្តីសុំការពិចារណាឡើងវិញ” ចៅក្រមនៅជំណាក់កាលមុនឧទ្ធរណ៍, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Popović* សំណុំរឿងលេខ IT-05-88-T “សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី សុំការពិចារណាឡើងវិញ ឬការបំភ្លឺអំពីសេចក្តីសម្រេចទទួលយកវត្ថុតាងជាមួយនឹងសក្ខីកម្មរបស់សាក្សី” អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ទំព័រ ៤ ដល់ ៥។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Jean-Bosco Barayagwiza* សំណុំរឿងលេខ ICTR-99-52A-R “សេចក្តីសម្រេចលើសំណើរបស់ Jean-Bosco Barayagwiza សុំការពិនិត្យឡើងវិញ និង/ឬការពិចារណាឡើងវិញលើសាលដីកាចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧” អង្គជំនុំជម្រះឧទ្ធរណ៍, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ២២ ដល់ ២៣។

ដំបូងតែប៉ុណ្ណោះ[10] ដោយសារតែ នីតិវិធីបែបនេះ គឺជាករណីពិសេស ហើយពុំមែនជាលទ្ធភាពបន្ថែមដែលត្រូវផ្តល់ឱ្យធ្វើការតវ៉ាក្តីសាឡើងវិញលើបញ្ហាដែលត្រូវបានពិភាក្សា ពិចារណា និងសម្រេចរួចហើយនោះឡើយ,

**ដោយពិចារណាឃើញ**ថា ក្នុងរឿងក្តីបច្ចុប្បន្ននេះ សំណើរបស់ នួន ជា សុំការពិចារណាឡើងវិញ ត្រូវបានចម្លងតាមអំណះអំណាងដែលបានលើកឡើងរួចមកហើយនៅក្នុងសំណើសុំកាលពីមុន អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានហេតុផលណាមួយគួរឱ្យជឿបាន ដែលត្រូវធ្វើការពិចារណាលើសេចក្តីសម្រេចរបស់ខ្លួនពីដំបូងឡើងវិញឡើយ,

**ដោយពិចារណាឃើញ**ថា អង្គជំនុំជម្រះតុលាការកំពូល នឹងត្រូវផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចលើភស្តុតាងបន្ថែម ប៉ុន្តែ ដោយសារគោលបំណងនៃប្រសិទ្ធភាពផ្នែកនីតិវិធី និងដើម្បីជៀសវាងការពិភាក្សាលើបញ្ហានៃភស្តុតាងដែលមានលក្ខណៈទូលំទូលាយនៅពេលនេះ ទើបអង្គជំនុំជម្រះសម្រេចថា នឹងផ្តល់សំអាងហេតុនៅពេលក្រោយ គឺនៅក្នុងសាលដីកាលើបណ្តឹងសាទុក្ខដែលនៅចំពោះមុខ,

**ពិចារណាឃើញ**ថា ការផ្អាកក្នុងការផ្តល់សំអាងហេតុ ពុំបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនៅក្នុងដំណើរការនីតិវិធីរបស់ នួន ជា ដោយហេតុថា សេចក្តីសម្រេចលើភស្តុតាងបន្ថែមនេះ ពុំអាចប្តឹងសាទុក្ខបានឡើយ ហើយការតវ៉ាផ្នែកនីតិវិធីដទៃទៀតដែលបានធ្វើឡើងដោយ នួន ជា តាមផ្លូវច្បាប់ ពុំបានពឹងផ្អែកលើអត្ថិភាពបន្ទាន់នៃសំអាងហេតុទាំងនេះឡើយ,

---

[10] សេចក្តីសម្រេចលើការលើកឡើងរបស់សហព្រះរាជអាជ្ញាស្តីពីការបន្តនីតិវិធីលើបណ្តឹងសាទុក្ខ, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ F30/16/1 ទំព័រ ៣។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើដែលបានដាក់ជាថ្មី សុំអន្តរាគមន៍ ឬដាក់សារណា*របស់អ្នកដែលពុំមែនជាភាគីក្នុងរឿងក្តី* ក្នុងសំណុំរឿង ០០២/០១, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ F31/1 ទំព័រ ៣។

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F2/10/3

**អាស្រ័យហេតុនេះ÷**

**-សម្រេចបដិសេធ**សំណើនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**